រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៦៧៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ស ម្រេ ច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិពី**អនុមន្ត្រី** ទៅឋានន្តរស័ក្តិ**វរមន្ត្រី** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នូវមន្ត្រីរាជការស៊ីវិល នៃទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម ÷

១	លោក សេង សាវន	ពី**អនុមន្ត្រី**ថ្នាក់លេខ ៤	ទៅជា**វរមន្ត្រី**ថ្នាក់លេខ ៦

២	លោក ទូច សំអាត	ពីអនុមន្ត្រីថ្នាក់លេខ ៤	ទៅជាវរមន្ត្រីថ្នាក់លេខ ៦
៣	លោក ឃុយ ហៀង	ពីអនុមន្ត្រីថ្នាក់លេខ ៥	ទៅជាវរមន្ត្រីថ្នាក់លេខ ៧
៤	លោក និត ហ៊ែល	ពីអនុមន្ត្រីថ្នាក់លេខ ៥	ទៅជាវរមន្ត្រីថ្នាក់លេខ ៧
៥	លោក គួច សុផារ៉ា	ពីអនុមន្ត្រីថ្នាក់លេខ ៦	ទៅជាវរមន្ត្រីថ្នាក់លេខ ៧
៦	លោក ប៊ិច លាងហ៊ី	ពីអនុមន្ត្រីថ្នាក់លេខ ៦	ទៅជាវរមន្ត្រីថ្នាក់លេខ ៧
៧	លោក ណូ សម្បុក	ពីអនុមន្ត្រីថ្នាក់លេខ ៦	ទៅជាវរមន្ត្រីថ្នាក់លេខ ៧
៨	លោក សយ សុខាន់	ពីអនុមន្ត្រីថ្នាក់លេខ ៧	ទៅជាវរមន្ត្រីថ្នាក់លេខ ៨
៩	លោក ចាន់ រ៉ាស៊ី	ពីអនុមន្ត្រីថ្នាក់លេខ ៧	ទៅជាវរមន្ត្រីថ្នាក់លេខ ៨
១០	លោក ស៊ុំ រុំ	ពីអនុមន្ត្រីថ្នាក់លេខ ៧	ទៅជាវរមន្ត្រីថ្នាក់លេខ ៨
១១	លោក តិច សំណាង	ពីអនុមន្ត្រីថ្នាក់លេខ ៩	ទៅជាវរមន្ត្រីថ្នាក់លេខ ៩
១២	លោកស្រី ហង្ស វុឌ្ឍី	ពីអនុមន្ត្រីថ្នាក់លេខ ៩	ទៅជាវរមន្ត្រីថ្នាក់លេខ ៩
១៣	លោក ញ៉ឹម បូម៉ាន	ពីអនុមន្ត្រីថ្នាក់លេខ ៩	ទៅជាវរមន្ត្រីថ្នាក់លេខ ៩
១៤	លោក ឃាង ច័ន្ទតារា	ពីអនុមន្ត្រីថ្នាក់លេខ ៩	ទៅជាវរមន្ត្រីថ្នាក់លេខ ៩
១៥	លោក ស៊ូ សុផាន	ពីអនុមន្ត្រីថ្នាក់លេខ ១០	ទៅជាវរមន្ត្រីថ្នាក់លេខ ១០
១៦	លោក ឈន ថុង	ពីអនុមន្ត្រីថ្នាក់លេខ ១០	ទៅជាវរមន្ត្រីថ្នាក់លេខ ១០
១៧	លោក ឡោ ប៊ូលីណា	ពីអនុមន្ត្រីថ្នាក់លេខ ១០	ទៅជាវរមន្ត្រីថ្នាក់លេខ ១០
១៨	លោកស្រី នាង លីណា	ពីអនុមន្ត្រីថ្នាក់លេខ ១០	ទៅជាវរមន្ត្រីថ្នាក់លេខ ១០
១៩	លោក សាបូ អូហ្សាណូ	ពីអនុមន្ត្រីថ្នាក់លេខ ១០	ទៅជាវរមន្ត្រីថ្នាក់លេខ ១០
២០	លោក ស៊ុន សួត	ពីអនុមន្ត្រីថ្នាក់លេខ ១០	ទៅជាវរមន្ត្រីថ្នាក់លេខ ១០
២១	លោក កើត សេកាណូ	ពីអនុមន្ត្រីថ្នាក់លេខ ១១	ទៅជាវរមន្ត្រីថ្នាក់លេខ ១០
២២	លោក ឆាយ ថៃ	ពីអនុមន្ត្រីថ្នាក់លេខ ១១	ទៅជាវរមន្ត្រីថ្នាក់លេខ ១០
២៣	លោក សេង សត្ថា	ពីអនុមន្ត្រីថ្នាក់លេខ ១១	ទៅជាវរមន្ត្រីថ្នាក់លេខ ១០
២៤	លោក ស៊ុំ ឈុំឡុង	ពីអនុមន្ត្រីថ្នាក់លេខ ១១	ទៅជាវរមន្ត្រីថ្នាក់លេខ ១០
២៥	លោក នុត សម្បត្តិ	ពីអនុមន្ត្រីថ្នាក់លេខ ១១	ទៅជាវរមន្ត្រីថ្នាក់លេខ ១០
២៦	លោក ជូរ គារី	ពីអនុមន្ត្រីថ្នាក់លេខ ១១	ទៅជាវរមន្ត្រីថ្នាក់លេខ ១០
២៧	លោក សុខ ទូច	ពីអនុមន្ត្រីថ្នាក់លេខ ១១	ទៅជាវរមន្ត្រីថ្នាក់លេខ ១០
២៨	លោក ឆេង វណ្ណារិទ្ធ	ពីអនុមន្ត្រីថ្នាក់លេខ ១១	ទៅជាវរមន្ត្រីថ្នាក់លេខ ១០

២៩	លោក ហាក់ ធីរោ	ពី**អនុមន្ត្រី**ថ្នាក់លេខ ១១	ទៅជា**វរមន្ត្រី**ថ្នាក់លេខ ១០
៣០	លោក ចាន់ ប៊ុន្នី	ពី**អនុមន្ត្រី**ថ្នាក់លេខ ១១	ទៅជា**វរមន្ត្រី**ថ្នាក់លេខ ១០
៣១	លោក សន ពៅ	ពី**អនុមន្ត្រី**ថ្នាក់លេខ ១១	ទៅជា**វរមន្ត្រី**ថ្នាក់លេខ ១០
៣២	លោក នូ ចាន់សុភី	ពី**អនុមន្ត្រី**ថ្នាក់លេខ ១១	ទៅជា**វរមន្ត្រី**ថ្នាក់លេខ ១០
៣៣	លោកស្រី សម សុភាព	ពី**អនុមន្ត្រី**ថ្នាក់លេខ ១១	ទៅជា**វរមន្ត្រី**ថ្នាក់លេខ ១០
៣៤	លោក កេត សោផាន់	ពី**អនុមន្ត្រី**ថ្នាក់លេខ ១១	ទៅជា**វរមន្ត្រី**ថ្នាក់លេខ ១០
៣៥	លោក ឆាយ ឆត្រាវុធ	ពី**អនុមន្ត្រី**ថ្នាក់លេខ ១១	ទៅជា**វរមន្ត្រី**ថ្នាក់លេខ ១០
៣៦	លោក វ៉ែន ចាវ័ត្ត	ពី**អនុមន្ត្រី**ថ្នាក់លេខ ១១	ទៅជា**វរមន្ត្រី**ថ្នាក់លេខ ១០
៣៧	លោក គួន ផេង	ពី**អនុមន្ត្រី**ថ្នាក់លេខ ១១	ទៅជា**វរមន្ត្រី**ថ្នាក់លេខ ១០
៣៨	លោក សួស យ៉ារ៉ា	ពី**អនុមន្ត្រី**ថ្នាក់លេខ ១១	ទៅជា**វរមន្ត្រី**ថ្នាក់លេខ ១០

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេចនិងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧០ អនក្រ-តត

អនុក្រឹត្យ

ស្តីពី

ការធ្វើសមាហរណកម្មមន្ត្រីរាជការ ទៅក្នុងក្របខ័ណ្ឌ មន្ត្រីក្រមការ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៩៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ស ម្រេ ច

មាត្រា ១ : ត្រូវបានធ្វើសមាហរណកម្មទៅក្នុងឋានន្តរស័ក្តិ **នាយក្រមការ** នៃក្របខ័ណ្ឌមន្ត្រីក្រមការ ទីស្តីការ-គណៈរដ្ឋមន្ត្រី នូវមន្ត្រីរាជការស៊ីវិល ដូចមានរាយនាមខាងក្រោម ÷

១	លោក យិន ណេន	នាយក្រមការ	ថ្នាក់លេខ ១

២	លោក អ៊ូ ងួនជរ	នាយក្រមការ	ថ្នាក់លេខ ១
៣	លោកស្រី ហៀង ស៊ុយអេលីន	នាយក្រមការ	ថ្នាក់លេខ ១
៤	លោក គង់ ស៊ីផុន	នាយក្រមការ	ថ្នាក់លេខ ២
៥	លោក សុខ គី	នាយក្រមការ	ថ្នាក់លេខ ២
៦	លោក សុខ គង់	នាយក្រមការ	ថ្នាក់លេខ ៣
៧	លោក ម៉ៅ យ៉ុន	នាយក្រមការ	ថ្នាក់លេខ ៣
៨	លោក គង់ តារី	នាយក្រមការ	ថ្នាក់លេខ ៣
៩	លោក ស៊ុយ ស៊ីផុន	នាយក្រមការ	ថ្នាក់លេខ ៣
១០	លោក ប្រាក់ សំអាន	នាយក្រមការ	ថ្នាក់លេខ ៣
១១	លោក នូ រិទ្ធី	នាយក្រមការ	ថ្នាក់លេខ ៣
១២	លោក ហ៊ីម វិបុលសុខ	នាយក្រមការ	ថ្នាក់លេខ ៣
១៣	លោកស្រី រស់ សុខាល	នាយក្រមការ	ថ្នាក់លេខ ៣
១៤	លោកស្រី ជា សាម៉ុល	នាយក្រមការ	ថ្នាក់លេខ ៣
១៥	លោក ប៉ែន សុផល	នាយក្រមការ	ថ្នាក់លេខ ៣
១៦	លោក អ៊ុក សុខ	នាយក្រមការ	ថ្នាក់លេខ ៤
១៧	លោកស្រី ពាង សុវណ្ណារី	នាយក្រមការ	ថ្នាក់លេខ ៤
១៨	លោក ឈុន លីម	នាយក្រមការ	ថ្នាក់លេខ ៤
១៩	លោក ព្រំ សំអុល	នាយក្រមការ	ថ្នាក់លេខ ៤
២០	លោក ឈុន ហ៊ាង	នាយក្រមការ	ថ្នាក់លេខ ៥
២១	លោក អ៊ឹម សុផល	នាយក្រមការ	ថ្នាក់លេខ ៥
២២	លោក គីម ស្រ៊ុង	នាយក្រមការ	ថ្នាក់លេខ ៥
២៣	លោកស្រី កៅ សារ៉ែន	នាយក្រមការ	ថ្នាក់លេខ ៥
២៤	លោកស្រី ទុង ធានី	នាយក្រមការ	ថ្នាក់លេខ ៥
២៥	លោកស្រី អួក ដារី	នាយក្រមការ	ថ្នាក់លេខ ៥
២៦	លោកស្រី គង់ វណ្ណា	នាយក្រមការ	ថ្នាក់លេខ ៥
២៧	លោក ជា អាយ	នាយក្រមការ	ថ្នាក់លេខ ៥
២៨	លោកស្រី ទេព សុទ្ធី	នាយក្រមការ	ថ្នាក់លេខ ៥

3

២៩	លោក ពៅ សុភាព	នាយក្រមការ	ថ្នាក់លេខ ៥
៣០	លោក ជា សាន	នាយក្រមការ	ថ្នាក់លេខ ៥
៣១	លោក ម៉ម ឈាន	នាយក្រមការ	ថ្នាក់លេខ ៥
៣២	លោក កុក លាង	នាយក្រមការ	ថ្នាក់លេខ ៥
៣៣	លោកស្រី ជា ដារីន	នាយក្រមការ	ថ្នាក់លេខ ៥
៣៤	លោក សួស វិសុទ្ធ	នាយក្រមការ	ថ្នាក់លេខ ៥
៣៥	លោក អ៊ុង ចន្ទូ	នាយក្រមការ	ថ្នាក់លេខ ៥
៣៦	លោក ទូច ខេមរិទ្ធ	នាយក្រមការ	ថ្នាក់លេខ ៥
៣៧	លោក អឿ សារ៉ន	នាយក្រមការ	ថ្នាក់លេខ ៦
៣៨	លោក ចាន់ ថា	នាយក្រមការ	ថ្នាក់លេខ ៦
៣៩	លោក អ៊ុម ខេមកោ	នាយក្រមការ	ថ្នាក់លេខ ៦
៤០	លោក សេន ស៊ីណា	នាយក្រមការ	ថ្នាក់លេខ ៦
៤១	លោក ឈាវ ណាក់	នាយក្រមការ	ថ្នាក់លេខ ៦

មាត្រា ២ : ត្រូវបានធ្វើសមាហរណកម្មទៅក្នុងឋានន្តរស័ក្តិ **ក្រមការដើមខ្សែ** នៃក្របខ័ណ្ឌមន្ត្រីក្រមការ ទីស្តីការ-គណៈរដ្ឋមន្ត្រី នូវមន្ត្រីរាជការស៊ីវិល ដូចមានរាយនាមខាងក្រោម ÷

១	លោក អ៊ិន សុខវ៉េង	ក្រមការដើមខ្សែ	ថ្នាក់លេខ ៣
២	លោក ហែម សៀន	ក្រមការដើមខ្សែ	ថ្នាក់លេខ ៣
៣	លោកស្រី បូ រ៉ា	ក្រមការដើមខ្សែ	ថ្នាក់លេខ ៣
៤	លោកស្រី ខឹម ណារី	ក្រមការដើមខ្សែ	ថ្នាក់លេខ ៣
៥	លោក ពៅ សឿន	ក្រមការដើមខ្សែ	ថ្នាក់លេខ ៤
៦	លោកស្រី វៀល សុផេត	ក្រមការដើមខ្សែ	ថ្នាក់លេខ ៤
៧	លោកស្រី ញ៉ែម ស៊ីណាត	ក្រមការដើមខ្សែ	ថ្នាក់លេខ ៤
៨	លោក សោម សាញ់	ក្រមការដើមខ្សែ	ថ្នាក់លេខ ៤
៩	លោកស្រី ហែម លន	ក្រមការដើមខ្សែ	ថ្នាក់លេខ ៤
១០	លោកស្រី នួន ប៊ុនធឿន	ក្រមការដើមខ្សែ	ថ្នាក់លេខ ៤
១១	លោកស្រី សូ សារិន	ក្រមការដើមខ្សែ	ថ្នាក់លេខ ៤
១២	លោកស្រី ផន វ៉ាន់នី	ក្រមការដើមខ្សែ	ថ្នាក់លេខ ៤

១៣	លោកស្រី ជា សាមឿន	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៤
១៤	លោកស្រី ប៊ុក សុខុន	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៤
១៥	លោក សុខ វុឌ្ឍី	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៤
១៦	លោក ខៀវ ច័ន្ទមុនី	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៤
១៧	លោកស្រី លឹម ស៊ីដេពីន	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៤
១៨	លោកស្រី ឈិន វួចម៉េង	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៤
១៩	លោក ចេង វុត្ថា	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៥
២០	លោកស្រី ជា វុណ្ណា	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៥
២១	លោក ឈឹម ចាន់ណាង	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៥
២២	លោកស្រី ប្រាក់ ម៉ាលី	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៥
២៣	លោក ហៃ សំអុល	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៥
២៤	លោក អ៊ុក សាអឿន	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៥
២៥	លោក ប៉ោ ឆេង	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៥
២៦	លោក មាស ភីរុណ	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៥
២៧	លោកស្រី មាស តុន្នី	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៥
២៨	លោកស្រី ប៊ុន សុភី	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៥
២៩	លោកស្រី ស សំណាង	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៥
៣០	លោក ប៉ាន់ ស៊ីវន	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៥
៣១	លោក សុខ សាន្ត	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៥
៣២	លោក ហុក ប៊ុនរ៉ង	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៥
៣៣	លោក ខៀវ សុទ្ធ	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៥
៣៤	លោក គួប ស្នេះ	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៦
៣៥	លោក អ៊ុក សុផល	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៦
៣៦	លោកស្រី ឈុន សុគន្ធ	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៦
៣៧	លោកស្រី ម៉ម ប៊ុនថា	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៦
៣៨	លោកស្រី ជា ចាន់ធឿន	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៦
៣៩	លោកស្រី អ៊ុង ចាន់ធី	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៦

5

៤០	លោកស្រី មាស ឡា	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៦
៤១	លោក ចេង សុវណ្ណ	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៦
៤២	លោក ជុំ លី	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៦
៤៣	លោក មាស ហ៊ិត	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៦
៤៤	លោក សារី ជុង	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៧
៤៥	លោកស្រី ហង្ស ច័ន្ទម៉ូលី	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៧
៤៦	លោក អ៊ុម ឃាងលី	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៧
៤៧	លោក សាយ បាន	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៧
៤៨	លោក ស្វាយ សំអុល	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៧
៤៩	លោក ឃុត សុទ្ធី	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៧
៥០	លោកស្រី ប៉ក់សម័យ សុរិទ្យានី	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៨
៥១	លោក ស្វាយ ដួត	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៨
៥២	លោក ប៊ិន សាឯម	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៩
៥៣	លោក ប៉ុល សួលី	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៩
៥៤	លោកស្រី ច្រឹង វណ្ណារ៉ា	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៩
៥៥	លោកស្រី នូវ លក្ខណា	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៩
៥៦	លោកស្រី ហង្ស បូរ៉ារី	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៩
៥៧	លោក ពៅ ភីរ៉ា	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៩
៥៨	លោក នួន សុគន្ធ	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៩
៥៩	លោក មៀច ម៉ុន	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៩
៦០	លោក សួស ប៊ុនថន	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៩
៦១	លោកស្រី ហៅ រិទ្ធ	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៩
៦២	លោកស្រី អ៊ឹម ចន្ទសិរី	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៩
៦៣	លោកស្រី ឡេប ស៊ីវ៉ាតារ៉ាឡែន	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៩
៦៤	លោក ឈឹម ចាន់ដន	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៩
៦៥	លោកស្រី ស៊ិន ដាវី	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៩
៦៦	លោកស្រី សូ សុខា	ក្រុមការដើមខ្សែ	ថ្នាក់លេខ ៩

៦៧	លោកស្រី គង់ បូផាណា	ក្រុមការជើមខ្សែ	ថ្នាក់លេខ ៩
៦៨	លោកស្រី ហាក់ ប៉ោលាង	ក្រុមការជើមខ្សែ	ថ្នាក់លេខ ៩
៦៩	លោក កែវ សម្បត្តិ	ក្រុមការជើមខ្សែ	ថ្នាក់លេខ ៩

មាត្រា ៣ : ត្រូវបានធ្វើសមាហរណកម្មទៅក្នុងឋានន្តរស័ក្តិ ក្រុមការ នៃក្របខ័ណ្ឌមន្ត្រីក្រុមការទីស្តីការគណៈរដ្ឋមន្ត្រី នូវមន្ត្រីរាជការស៊ីវិល ដូចមានរាយនាមខាងក្រោម÷

១	លោកស្រី ផ្លុង ធារោ	ក្រុមការ	ថ្នាក់លេខ ១
២	លោក វ៉ង់ ស៊ីវុន	ក្រុមការ	ថ្នាក់លេខ ៤
៣	លោក ដាវ យ៉ាន	ក្រុមការ	ថ្នាក់លេខ ៤
៤	លោក ឈន ឈុនថាយ	ក្រុមការ	ថ្នាក់លេខ ៤
៥	លោក ចាប សំណាង	ក្រុមការ	ថ្នាក់លេខ ៥
៦	លោក អាំ ថាំ	ក្រុមការ	ថ្នាក់លេខ ៥
៧	លោក ជ័យ ខ្លឹង	ក្រុមការ	ថ្នាក់លេខ ៦
៨	លោកស្រី ស៊ាង ស៊ីណាត	ក្រុមការ	ថ្នាក់លេខ ៦
៩	លោក តាំង ម៉េងហ៊ាង	ក្រុមការ	ថ្នាក់លេខ ៧
១០	លោក ឱម សម្បត្តិ	ក្រុមការ	ថ្នាក់លេខ ៨
១១	លោកស្រី ធី សុទ្ធារី	ក្រុមការ	ថ្នាក់លេខ ៨
១២	លោកស្រី ង៉ែត ចាក់	ក្រុមការ	ថ្នាក់លេខ ៩
១៣	លោកស្រី កៅ ស៊ីរី	ក្រុមការ	ថ្នាក់លេខ ១០
១៤	លោក ថៃ ខុនលី	ក្រុមការ	ថ្នាក់លេខ ១១
១៥	លោក នា ស៊ីថា	ក្រុមការ	ថ្នាក់លេខ ១១
១៦	លោក ឯក សារ៉ា	ក្រុមការ	ថ្នាក់លេខ ១១
១៧	លោក ខន កែវមនោ	ក្រុមការ	ថ្នាក់លេខ ១១
១៨	លោក ស៊ុន សេរីវុធ	ក្រុមការ	ថ្នាក់លេខ ១១
១៩	លោក ឡេង លាត	ក្រុមការ	ថ្នាក់លេខ ១១
២០	លោក ធុច បញ្ញសន្តិភាព	ក្រុមការ	ថ្នាក់លេខ ១១
២១	លោក ប៉ោត ចាន់ណារី	ក្រុមការ	ថ្នាក់លេខ ១២
២២	លោក ព្រុំ ចក់	ក្រុមការ	ថ្នាក់លេខ ១២

២៣	លោក ស៊ុក សំនិត	ក្រមការ	ថ្នាក់លេខ ១២
២៤	លោក ព្រួ ស៊ីថន	ក្រមការ	ថ្នាក់លេខ ១២
២៥	លោក កែវ ភក្តី	ក្រមការ	ថ្នាក់លេខ ១២
២៦	លោក ធន់ ប៊ុនធឿន	ក្រមការ	ថ្នាក់លេខ ១២
២៧	លោកស្រី ឃុន រ៉ូហ្សាលី	ក្រមការ	ថ្នាក់លេខ ១៣
២៨	លោក ផន សុភាព	ក្រមការ	ថ្នាក់លេខ ១៣
២៩	លោក គាន ឆន	ក្រមការ	ថ្នាក់លេខ ១៣
៣០	លោក ឈុន ប៊ុនគា	ក្រមការ	ថ្នាក់លេខ ១៣
៣១	លោក អ៊ឹម សូម៉ាដា	ក្រមការ	ថ្នាក់លេខ ១៣
៣២	លោកស្រី ហាស់ សុទ្ធារី	ក្រមការ	ថ្នាក់លេខ ១៣
៣៣	លោក ណុប សុធារ៉ា	ក្រមការ	ថ្នាក់លេខ ១៣
៣៤	លោក លី ដាណា	ក្រមការ	ថ្នាក់លេខ ១៣
៣៥	លោកស្រី ខូយ សិរីសោភា	ក្រមការ	ថ្នាក់លេខ ១៤
៣៦	លោក ចាន់ សុផាន់ណា	ក្រមការ	ថ្នាក់លេខ ១៤
៣៧	លោក សិទ្ធី សូណា	ក្រមការ	ថ្នាក់លេខ ១៤
៣៨	លោក ហាយ ស៊ុន	ក្រមការ	ថ្នាក់លេខ ១៤
៣៩	លោកស្រី បូ សូលីដា	ក្រមការ	ថ្នាក់លេខ ១៤
៤០	លោក ទេព កោសល្យ	ក្រមការ	ថ្នាក់លេខ ១៤
៤១	លោក អ៊ុក វឌ្ឍនា	ក្រមការ	ថ្នាក់លេខ ១៤
៤២	លោក ជុំ គីមរ៉ុង	ក្រមការ	ថ្នាក់លេខ ១៤
៤៣	លោក គង់ តុលា	ក្រមការ	ថ្នាក់លេខ ១៤
៤៤	លោក អែតដា ដូរ៉ាមី	ក្រមការ	ថ្នាក់លេខ ១៤
៤៥	លោក កើត ហ៊ន	ក្រមការ	ថ្នាក់លេខ ១៤
៤៦	លោក ស៊ាត អុល	ក្រមការ	ថ្នាក់លេខ ១៤
៤៧	លោក ទេព ផល្គុណ	ក្រមការ	ថ្នាក់លេខ ១៤
៤៨	លោកស្រី មាស មករា	ក្រមការ	ថ្នាក់លេខ ១៤

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនឹងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនិងឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៤

-រាជកិច្ច ✓

-ឯកសារ-កាលប្បវត្តិ.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៨១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតម្លើងឋានន្តរស័ក្តិនាយទាហានជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គមេបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យ លេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

សម្រេច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៩ រូប ដូចមានរាយនាមខាងក្រោម :

១- វរសេនីយ៍ទោ **យូ សិរីវុឌ្ឍ** អត្តលេខ ០១៩៧០៣

២- វរសេនីយ៍ទោ **មាស ស៊ីផាន** អត្តលេខ ០១៧២៦៥

៣- វរសេនីយ៍ទោ **ឈួច ចំណាន** អត្តលេខ ០៤២៩៣៧

៤- វរសេនីយ៍ទោ **ដួង វិបុល** អត្តលេខ ០៤៣៨៣១

៥- វរសេនីយ៍ទោ **ម៉ៅ គន្ធា** អត្តលេខ ០១២៩៨៣

៦- វរសេនីយ៍ទោ **សេង ហួត** អត្តលេខ ០០៣៧៩០

៧- វរសេនីយ៍ទោ **ស្រួង ម៉ាន់ឌី** អត្តលេខ ២៣១៤៩៨

៨- វរសេនីយ៍ទោ **ហូ សិទ្ធិគុណ** អត្តលេខ ២៣២០១៣

៩- វរសេនីយ៍ទោ **សេង គុកហ៊ាង** អត្តលេខ ២៣១៧០២

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦៨៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **គីម សខាត** ជាជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៦៥ សសរ

សេចក្ដីសម្រេច

ស្ដីពី

ការអនុវត្តន៍ស្ដង់ដាសកម្មភាពកំចាត់មីនកម្ពុជា ៥ ជំពូក

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្ដីពី ការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្ដីពីវិសោធនកម្មមាត្រា ៤ មាត្រា ១០ និង មាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្ដីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៨៦ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៥ ស្ដីពីការតែងតាំងសមាសភាពអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

ប្រការ ១ :

ត្រូវបានដាក់អោយអនុវត្តនូវស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ៥ជំពូក ដូចខាងក្រោម :

- ជំពូក ១. ការអនុវត្តស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា
- ជំពូក ២. ប័ណ្ណទទួលស្គាល់អង្គការប្រតិបត្តិករសកម្មភាពកំចាត់មីន និង ការផ្តល់អាជ្ញាប័ណ្ណសម្រាប់កិច្ចប្រតិបត្តិការ
- ជំពូក ៣. ការត្រួតពិនិត្យប្រតិបត្តិករដោះមីន
- ជំពូក ៤. ការរក្សាទុក ការដឹកជញ្ជូន និង ការប្រើប្រាស់គ្រឿងផ្ទុះ
- ជំពូក ៥. សេចក្តីរាយការណ៍ និង ការអង្កេតឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងពេលដោះមីន ។

ប្រការ ២ :

គ្រប់ប្រតិបត្តិករដែលមានបំណងធ្វើសកម្មភាពបោសសំអាតមីន ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យសុំប័ណ្ណទទួលស្គាល់ និង ចុះកិច្ចសន្យាជាមួយអគ្គលេខាធិការអាជ្ញាធរមីន ។

ប្រការ ៣ :

ប្រតិបត្តិករដោះមីនជាតិ និង អន្តរជាតិ ដែលកំពុងបើកកិច្ចប្រតិបត្តិការបោសសំអាតមីននៅកម្ពុជា ត្រូវមកបំពេញបែបបទចុះកិច្ចសន្យា ដើម្បីធ្វើនិយតកម្មជាមួយអគ្គលេខាធិការអាជ្ញាធរមីន ក្នុងរយៈពេល ៦ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះ ។

ប្រការ ៤ :

អគ្គលេខាធិការដ្ឋានអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ត្រូវរៀបចំចងក្រងគោលការណ៍ណែនាំលំអិត ដើម្បីអនុវត្តនូវស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា អោយមានប្រសិទ្ធភាព ។

ប្រការ ៥ :

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ និង អគ្គលេខាធិការអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

com2doc/BOREIY HOTEL

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៧០...សសរ

សេចក្តីសម្រេច

ស្តីពី

ការកែសម្រួលគណៈកម្មការអន្តរក្រសួងដើម្បីបន្តដោះស្រាយគោលនយោបាយ ដីធ្លីជាមួយប្រជាពលរដ្ឋ នៅបុរីវប្បធម៌-ទេសចរណ៍អង្គរសៀមរាប គ្រប់គ្រងដោយអាជ្ញាធរអប្សរា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា " អាជ្ញាធរអប្សរា "

-បានឃើញអនុក្រឹត្យលេខ ៧៩/អនក្រ/បក ចុះថ្ងៃទី១៣ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពី បុរីសណ្ឋាគារ

-បានឃើញអនុក្រឹត្យលេខ ៩៣/អនក្រ/បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីអំពីការពង្រីកផ្ទៃដីបុរីសណ្ឋាគារអង្គរសៀមរាបគ្រប់គ្រងដោយអាជ្ញាធរអប្សរា

-យោងតាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និង អាជ្ញាធរអប្សរា ។

ស ម្រេ ច

ប្រការ១. – ចាត់ទុកជានិរាករណ៍ នូវសេចក្តីសម្រេចលេខ ៧១/សសរ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៩ និង សេចក្តីសម្រេចលេខ ៧៥/សសរ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០០១ ។

ប្រការ២. – បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីបន្តដោះស្រាយសម្របសម្រួលជាមួយប្រជាពលរដ្ឋ ដែលកាន់កាប់ដីធ្លីនៅបុរីវប្បធម៌-ទេសចរណ៍ អង្គរសៀមរាប គ្រប់គ្រងដោយអាជ្ញាធរអប្សរាដែលមានសមាសភាពដូចខាងក្រោម÷

១-ឯកឧត្តម	**ប៊ុន ណារិទ្ធ**	អគ្គនាយកអាជ្ញាធរអប្សរា	ប្រធាន
២-លោក	**សុខ លក្ខិណា**	អភិបាលរងខេត្តសៀមរាប	អនុប្រធាន
៣-ឯកឧត្តម	**ខូយ គឹមទូ**	ទីប្រឹក្សាប្រធានអាជ្ញាធរអប្សរា	អនុប្រធានអចិន្ត្រៃយ៍
៤-ឯកឧត្តម	**សួន ម៉េងគា**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	សមាជិក
៥-ឯកឧត្តម	**សួន ចាន់ថន**	មេធាវីរាជរដ្ឋាភិបាល	សមាជិក
៦-ឯកឧត្តម	**ឌុច ថននិតូ**	អគ្គនាយក នៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់	សមាជិក

គណៈកម្មការអន្តរក្រសួងនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ។

ប្រការ៣. – គណៈកម្មការអន្តរក្រសួងមានភារកិច្ច÷

ជំរុញការងារដោះស្រាយ បញ្ហាការកាន់កាប់ដីក្នុងទីតាំងបរិវេណបុរីវប្បធម៌-ទេសចរណ៍ ដែលកំណត់ដោយអនុក្រឹត្យលេខ ៧៩/អនក្រ បក ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីបុរីសណ្ឋាគារ និង អនុក្រឹត្យលេខ ៩៣/អនក្រ/បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីអំពីការពង្រីកផ្ទៃដីបុរីសណ្ឋាគារអង្គរសៀមរាបគ្រប់គ្រង ដោយអាជ្ញាធរអប្សរា។

ប្រការ៤. – ក្នុងទិសដៅធានាការពារផលប្រយោជន៍សាធារណៈ គណៈកម្មការអន្តរក្រសួងមានសិទ្ធិចាត់វិធានការសមស្របទាំងឡាយ ដោយយោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីអនុវត្តអនុក្រឹត្យ និងលិខិតបទដ្ឋានផ្សេងទៀតដែលទាក់ទងការងារដោះស្រាយគោលនយោបាយដីធ្លីក្នុង បុរីវប្បធម៌ - ទេសចរណ៍ ។

ប្រការ៥. – គណៈកម្មការអន្តរក្រសួងនេះមានក្រុមការងារមួយ ដែលត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងស្ថិតក្រោមការដឹកនាំរបស់អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មការអន្តរក្រសួង ដើម្បីអនុវត្តការងារផ្ទាល់នៅមូលដ្ឋាន ។ សមាសភាពរបស់ក្រុមការងារត្រូវបានបញ្ជូនមកពីក្រសួង អង្គភាព អាជ្ញាធរ នានាដែលពាក់ពន្ធ័តាមសំណើរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

ប្រការ៦.- បណ្ដាក្រសួង ស្ថាប័ន អង្គភាព អាជ្ញាធរដែលពាក់ពន្ធ័ ត្រូវចូលរួមសហប្រតិបត្តិការឱ្យបានពេញលេញជាមួយគណៈកម្មការអន្តរក្រសួងនេះ សំដៅឱ្យការដោះស្រាយគោលនយោបាយជាមួយប្រជាពលរដ្ឋបានទទួលលទ្ធផលវិជ្ជមានឆាប់រហ័ស ។

ប្រការ៧.- ថវិកាគោលនយោបាយសម្រាប់ចាត់ចែងសម្របសម្រួលផ្ដល់ជូនប្រជាពលរដ្ឋ ដែលត្រូវចេញពីបុរីវប្បធម៌-ទេសចរណ៍ និងបណ្ដាសោហ៊ុយចំណាយក្នុងដំណើរការដោះស្រាយដីធ្លីជាបន្ទុករបស់ អាជ្ញាធរអប្សរា ។

ប្រការ៨.- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៩.- ទីស្ដីការគណៈរដ្ឋមន្ត្រី អាជ្ញាធរអប្សរា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្រុមប្រឹក្សាអ្នកច្បាប់ សាលាខេត្តសៀមរាប គ្រប់ក្រសួង-ស្ថាប័ន អង្គភាពដែលពាក់ព័ន្ធ និង សាមីជន ដូចក្នុងប្រការ២ មានភារកិច្ចអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២ និងប្រការ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៥៧៤ ឧរម-កឧ-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៥

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ន.ស/ រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញលិខិតលេខ ១៩១៤/០៥ ត.វ.ក ចុះថ្ងៃទី១៥.០៦.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ខេ.អិន.ធី ប្រ៊ូវើរី ចុះថ្ងៃទី០៧.០៤.២០០៥ ។

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ខេ.អិន.ធី ប្រ៊ូវើរី (K.N.T BREWERY CO., LTD.) តំណាងដោយលោក ម៉ែន ចាន់សុខា សញ្ជាតិខ្មែរ អាយុ៥១ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ 010362039 ចុះថ្ងៃទី០៩.០៤.២០០២ បង្កើតរោងចក្រ "ផលិតស្រាបៀរ "ដែលមានឈ្មោះថា " ខេ.អិន.ធី ប្រ៊ូវើរី (K.N.T BREWERY) " មានទីតាំងស្ថិតនៅភូមិធន់មោង ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតម្កល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានសំរេចក្នុងរយៈពេល ៦ខែ ដោយគិតបញ្ចូលទាំងរយៈពេលសាកល្បងផង ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតស្រាបៀរ " ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ៧ : ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកំពង់ធំ និងប្រធានក្រុមហ៊ុន ខេ.អិន.ធី ប្រ៊ូវើរី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តកំពង់ធំ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ៥៧៥ ឧរ៥.កង-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៥

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ន.ស/ រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញលិខិតលេខ ៦៨០៨/០៥ គ.វ.ក ចុះថ្ងៃទី០៨.០៦.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អល ស៊ូបភើ អ៊ិនធើប្រាយ (ខេមបូឌា) ចុះថ្ងៃទី២៥.០៤.២០០៥ ។

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អល ស៊ូបភើ អ៊ិនធើប្រាយ (ខេមបូឌា) (All SUPER ENTERPRISE (CAMBODIA) LTD.) តំណាងដោយលោក HSU NAI-WEN សញ្ជាតិចិន (តៃវ៉ាន់) ភេទប្រុស អាយុ៤៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 200118853 ចុះថ្ងៃទី២០.១១.២០០២ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "អល ស៊ូបភើ អ៊ិនធើប្រាយ (ខេមបូឌា) (ALL SUPER ENTERPRISE (CAMBODIA))" មានទីតាំងស្ថិតនៅភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន អល ស៊ូបភើ អ៊ិនធើប្រាយ (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

N°៥៧១ ឧស៤.គ១.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៥

ប្រ កា ស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញលិខិតលេខ ២១៦៨/០៥ គ.វ.ក ចុះថ្ងៃទី០១.០៧.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ឃីង ហ្វេសិន ហ្គាមេន ចុះថ្ងៃទី១៥.០៦.២០០៥ ។

ស ម្រេ ច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ឃីង ហ្វេសិន ហ្គាមេន (KING FASHION GARMENT CO., LTD.) តំណាងដោយលោក WANG YI-MING សញ្ជាតិចិន (តៃវ៉ាន់) អាយុ៤៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 200229987 ចុះថ្ងៃទី០៥.១២.២០០២ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ឃីង ហ្វេសិន ហ្គាមេន (KING FASHION GARMENT)" មានទីតាំងស្ថិតនៅ ភូមិត្រពាំងវែចេក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣

45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ឃីង ហ្វេសិន ហ្គាមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

" ដើម្បីជូនជ្រាប"

- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៥៧៧ ៦៨- កឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៥

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញលិខិតលេខ ២១៦៥/០៥ គ.វ.ក ចុះថ្ងៃទី០១.០៧.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- យោងពាក្យស្នើរបស់ក្រុមហ៊ុន មេរីត ហ្គាមេន ចុះថ្ងៃទី១៥.០៦.២០០៥ ។

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន មេរីត ហ្គាមេន (MERIT GARMENT CO., LTD.) តំណាងដោយលោក TSAI CHAO-LUN សញ្ជាតិចិន(តៃវ៉ាន់) អាយុ៥៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ132766270 ចុះថ្ងៃទី២៨.១២.២០០១ បង្កើតរោងចក្រ“កាត់ដេរសម្លៀកបំពាក់” ដែលមានឈ្មោះថា “មេរីត ហ្គាមេន (MERIT GARMENT)” មានទីតាំងស្ថិតនៅសួនឧស្សាហកម្មវឌ្ឍនៈ អាគារ! ផ្លូវចោមចៅ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន មេរីត ហ្គាមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៩ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៥៩៤ ឧរក.ឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៥

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញលិខិតលេខ ១៧៤០/០៥ ក.វ.ក ចុះថ្ងៃទី០៣.០៦.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- យោងពាក្យស្នើរបស់ក្រុមហ៊ុន បេសវ៉េយ អ៊ិនដាសស្ទ្រាល ចុះថ្ងៃទី២៥.០៧.២០០៥ ។

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន បេសវ៉េយ អ៊ិនដាសស្ទ្រាល (BESTWAY INDUSTRIAL CO., LTD.) តំណាងដោយលោក FANG WU -LEH សញ្ជាតិចិន (តៃវ៉ាន់) អាយុ៥៤ឆ្នាំ កាន់លិខិតឆ្លងដែនលេខ M17342641 ចុះថ្ងៃទី ០៧.០៣.២០០០ បង្កើតរោងចក្រ "ផលិតកង់ និង ម៉ូតូ" ដែលមានឈ្មោះថា "បេសវ៉េយ អ៊ិនដាសស្ទ្រាល (BESTWAY INDUSTRIAL)" មានទីតាំងស្ថិតនៅ ភូមិតាពៅ ឃុំបាវិត និង ភូមិថ្នាញ ឃុំបាទី ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុន ត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតកង់ និង ម៉ូតូ" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខ រោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់១ឆ្នាំ ក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តស្វាយរៀង និងប្រធានក្រុមហ៊ុន បេសវ៉េយ អ៊ិនដាសស្ត្រាល ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ទីស្តីការគណៈរដ្ឋមន្ត្រី

ស៊ុយ-សែម

ចម្លងជូន :
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -រាជកិច្ច
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- -ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងពាណិជ្ជកម្ម
- -សាលាខេត្តស្វាយរៀង

" ដើម្បីជូនជ្រាប"

- -ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ១៦៧៦ ពណ.នគក

ភ្នំពេញថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនវិនិយោគទុនឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ដាយមេន សាន់**
DIAMOND SUN CO.,LTD.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Inv. 961/05P ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន : លោកស្រី **អ៊ុក សិរីវឌ្ឍកល្យាណ**
៣- ដើមទុនក្រុមហ៊ុន : ចំនួន ៥០០.០០០ ដុល្លារអាមេរិក
៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៩C ផ្លូវលេខ ២៣២ សង្កាត់ផ្សារដេប៉ូទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។
៥- កម្មវត្ថុអាជីវកម្ម : - អាជីវកម្មខ្សាច់- គ្រួស
៦- ចិរវេលា : ៧០ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ-មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៤៨១ ពណ.នគក

ភ្នំពេញថ្ងៃទី ២០ ខែកក្កដាឆ្នាំ ២០០៥

សេចក្តីសម្រេច រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ថេកឃីង សូអីង ម៉ាស៊ីន**

TAKING SEWING MACHINE Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7889 /05P ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **អ៊ឹង វណ្ណារិទ្ធិ** ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី **ចុង ហ៊ុយស៊ាង** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២១ Eo ផ្លូវលេខ ១៣៨ សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
